**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៩១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១**.-

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាអប់រំកុមារតូច សេវាអប់រំបឋមសិក្សា និងសេវាអប់រំក្រៅប្រព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការបង្វិតការសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនេះឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

**មាត្រា២** .-

អនុក្រឹត្យនេះមានគោលដៅ៖
- ប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- ផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់

- កំណត់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគាំទ្រ និងអនុវត្តមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កំណត់គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធប្រកបដោយគុណភាព គណនេយ្យភាព ប្រសិទ្ធភាព និងសមធម៌។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗ។

## ជំពូកទី២

## ការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក

**មាត្រា៤.-**

ប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗ។

រដ្ឋបាលក្រុង ស្រុកទាំង១៤នៃខេត្តបាត់ដំបងត្រូវបានកំណត់ជារដ្ឋបាលក្រុង ស្រុកគោលដៅដែលត្រូវបានប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធចាប់ពីឆ្នាំ២០១៦។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវសហការជាមួយក្រសួងមហាផ្ទៃដើម្បីលើកសំណើសុំការសម្រេចពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអំពីរដ្ឋបាលក្រុង ស្រុកគោលដៅផ្សេងទៀត និងដំណាក់កាលបន្តបន្ទាប់នៃការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធចាប់ពីឆ្នាំ២០១៧តទៅ។

**មាត្រា៥.-**

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុករួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំកុមារតូច
- ការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា
- ការគ្រប់គ្រងសិស្ស
- ការរៀបចំផែនការសម្រាប់ការអប់រំកុមារតូច

- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំកុមារតូច
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនា សម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំកុមារតូច
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជនកម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ
- ការគ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូចដូចជាកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងកម្មវិធីមត្តេយ្យសិក្សាឯកជន។

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

**មាត្រា៦**.-

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សាដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅរួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំបឋមសិក្សា
- ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សាជាប់កិច្ចសន្យា
- ការគ្រប់គ្រងសិស្សបឋមសិក្សា
- ការរៀបចំផែនការសម្រាប់ការអប់រំបឋមសិក្សា
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំបឋមសិក្សា
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោល
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំបឋមសិក្សា
- ការគ្រប់គ្រងដំណើរការគណៈកម្មការទ្រទ្រង់សាលារៀន
- ការគ្រប់គ្រងដំណើរការគណៈកម្មការកម្រងសាលារៀន
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណសាលាបឋមសិក្សាឯកជនកម្មវិធីសិក្សាជាតិ
- ការគ្រប់គ្រងកម្មវិធីការងារគាំទ្រការអប់រំបឋមសិក្សា៖
    - កម្មវិធីពហុភាសា
    - កម្មវិធីពន្លឿនការសិក្សា
    - កម្មវិធីស្បៀងអាហារតាមសាលារៀន
    - កម្មវិធីអប់រំពិសេស
    - កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ
    - កម្មវិធីអប់រំសុខភាព និងអនាម័យ

- ការងារក្រុមប្រឹក្សាកុមារ
- ការងារអប់រំកាយ និងកីឡា

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សាជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៧**.-

មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅរួមមាន៖

- ការគ្រប់គ្រងបុគ្គលិកអប់រំ
- ការជ្រើសរើសនិងគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម
- ការរៀបចំផែនការសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមុខរបរ និងភាសាបរទេសរយៈពេលតិចជាង០១ (មួយ)ឆ្នាំ
- ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំក្រៅប្រព័ន្ធ
- ការគ្រប់គ្រងដំណើរការកម្មវិធី និងសេវាពាក់ព័ន្ធនឹង៖
  - កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ
  - កម្មវិធីក្រោយអក្ខរកម្ម
  - កម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា
  - កម្មវិធីបង្កើនប្រាក់ចំណូល
  - កម្មវិធីចូលរៀនឡើងវិញ

សកម្មភាពលម្អិតនៃមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

**មាត្រា៨**.-

គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣

## ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា៩.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង ស្រុកគោលដៅ ដើម្បីកំណត់អំពីកញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

ការកំណត់កញ្ចប់ធនធានហិរញ្ញវត្ថុ រូបមន្ត លក្ខណវិនិច្ឆ័យ ការបែងចែកធនធាន កាលវិភាគនៃការផ្ទេរ និងលក្ខខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគ្រោងឥណទានចំណាយសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ នៅក្នុងជំពូកចំណាយមិនបានគ្រោងទុកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនដំណឹងជាផ្លូវការទៅរដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ អំពីទំហំធនធានហិរញ្ញវត្ថុដែលត្រូវផ្ទេរសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅដាក់បញ្ចូលថវិកានេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ។

**មាត្រា១១.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្ទេរថវិកាសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗទៅតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ។

**មាត្រា១២.-**

រដ្ឋបាលក្រុង ស្រុកគោលដៅអាចប្រើប្រាស់ចំណែកធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់គាំទ្រដល់ការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់។

**មាត្រា១៣.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង ស្រុកគោលដៅដើម្បីកំណត់អំពីទ្រព្យសម្បត្តិដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់គាំទ្រអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា១៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាដើម្បីរៀបចំផ្ទេរទ្រព្យសម្បត្តិនានាដែលកំពុងប្រើប្រាស់សម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងទ្រព្យសម្បត្តិចាំបាច់ផ្សេងទៀតតាមការកំណត់ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់។

ការផ្ទេរទ្រព្យសម្បត្តិខាងលើនេះត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៥.-**

រដ្ឋបាលក្រុង ស្រុកគោលដៅត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរឱ្យសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធស្របតាមលក្ខខណ្ឌ និងនីតិវិធីនានាដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការផ្ទេរធនធានមនុស្ស

**មាត្រា១៦.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ រដ្ឋបាលក្រុង ស្រុកគោលដៅ និង

អង្គភាពពាក់ព័ន្ធនានាដើម្បីកំណត់អំពីប្រភេទ និងចំនួនបុគ្គលិកនៃការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកដែលកំពុងគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដើម្បីផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗ។

**មាត្រា១៧.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំផ្ទេរបុគ្គលិកដែលបានកំណត់ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅទៅតាមនីតិវិធីដែលបានកំណត់ដោយព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវមានលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងលក្ខខណ្ឌការងារ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួល។

**មាត្រា១៨.-**

ការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅត្រូវអនុលោមតាមព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុកគោលដៅ

**មាត្រា១៩.-**

ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកនៃក្រសួងអប់រំ យុវជន និងកីឡាឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកគោលដៅសាមីនីមួយៗ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យអប់រំ យុវជន និងកីឡាដែលត្រូវបានផ្ទេរឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកគោលដៅសាមីនីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា និងពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកដែលត្រូវបានផ្ទេរឱ្យមកស្ថិតក្រោមរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុកគោលដៅលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុក និងត្រូវបំពេញតួនាទីជាសេនាធិការឱ្យប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តលើការអនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការងារយុវជន ការងារកីឡា និងការងារផ្សេងទៀតដែលពុំទាន់បានប្រគល់មកឱ្យរដ្ឋបាលក្រុង ស្រុក។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវដាក់ចេញនូវសេចក្ដីណែនាំស្ដីពីការគ្រប់គ្រង និងការអនុវត្ត

មុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការងារយុវជន ការងារកីឡា និងការងារផ្សេងទៀតដែលពុំទាន់បានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក។

**មាត្រា២០.-**

រដ្ឋបាលក្រុង ស្រុកគោលដៅនីមួយៗត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងស្តង់ដាជាតិអប់រំ។

ដើម្បីអនុវត្តមុខងារទាំងនេះ រដ្ឋបាលក្រុង ស្រុកគោលដៅ៖

- ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក
- ត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលបានផ្ទេរសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់
- លើកសំណើសុំបង្កើត ប្រែក្លាយ បិទសាលាមត្តេយ្យសិក្សារដ្ឋ សាលាបឋមសិក្សារដ្ឋ
- លើកសំណើអំពីតម្រូវការបុគ្គលិកអប់រំ និងតម្រូវការនៃការបណ្តុះបណ្តាលបុគ្គលិក
- ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- អាចធ្វើប្រតិភូកម្មនូវមុខងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឱ្យដល់រដ្ឋបាលឃុំ សង្កាត់
- អាចកៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធតាមកាលកំណត់ ជូនមន្ទីរអប់រំ យុវជន និងកីឡាដើម្បីបូកសរុបជូនក្រសួងអប់រំ យុវជន និងកីឡា
- ត្រូវរៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធតាមកាលកំណត់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៦

## ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា២១.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់មុខងារ និងធនធាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅតាមដំណាក់កាលនីមួយៗដែលបានកំណត់ ព្រមទាំងត្រូវសម្របសម្រួលដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលក្រុង ស្រុកគោលដៅក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអប់រំ ស្តង់ដាជាតិអប់រំ គោលការណ៍ និងនីតិវិធីដែលបានកំណត់។

**មាត្រា២២.-**

ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ស្តង់ដាជាតិអប់រំ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- រៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន សៀវភៅសិក្សាគោលសម្រាប់ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដាអប្បបរមាសម្រាប់ផ្គត់ផ្គង់ និងការប្រើប្រាស់បុគ្គលិកពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់រដ្ឋបាលក្រុង ស្រុកគោលដៅ និងបុគ្គលិកអប់រំដែលត្រូវបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ
- ជ្រើសរើស បណ្តុះបណ្តាល បែងចែក និងក្រឹតការគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា
- វាយតម្លៃគុណភាពការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកគោលដៅអំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- កៀរគរធនធានពីប្រភពនានាសម្រាប់គាំទ្រដល់កម្មវិធី ឬសកម្មភាពនានាពាក់ព័ន្ធនឹងការកែលម្អគុណភាពនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដែលបានប្រគល់ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

ក្រសួងអប់រំ យុវជន និងកីឡាអាចធ្វើប្រតិភូកម្មជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្នុងការគាំទ្រ

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា២៣**.-

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកគោលដៅក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**មាត្រា២៤**.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រ និងតាមដានត្រួតពិនិត្យលើការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅសម្រាប់អនុវត្តមុខងារនានាពាក់ព័ន្ធនឹងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

**មាត្រា២៥**.-

ក្រសួងមុខងារសាធារណៈមានតួនាទីគាំទ្រដល់ការផ្ទេរបុគ្គលិកអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ និងតាមដាន ត្រួតពិនិត្យការចាត់ចែងបុគ្គលិកដែលបានផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកគោលដៅ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា២៦**.-

ក្នុងអំឡុងពេលដែលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរតណទានថវិកាមិនទាន់រៀបចំរួចរាល់ ការគ្រប់គ្រង ការចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវអនុវត្តតាមបែបបទ និងនីតិវិធីហិរញ្ញវត្ថុដែលកំពុងអនុវត្តបច្ចុប្បន្ន ដោយត្រូវរាយការណ៍ជូនក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកគោលដៅ។

**មាត្រា២៧**.-

ក្នុងអំឡុងពេលដែលលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ក្រសួងមុខងារសាធារណៈត្រូវដាក់ចេញជាបន្ទាន់នូវសេចក្តីណែនាំអំពីគោលការណ៍ បែបបទ និងនីតិវិធីដើម្បីធានាដល់ការផ្ទេរ និងការគ្រប់គ្រងបុគ្គលិកអប់រំដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៨**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**<u>កន្លែងទទួល៖</u>**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១៦១...អនក្រ.បក ចុះថ្ងៃទី១៤.....ខែកញ្ញា....ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក

| មុខងារ | សកម្មភាព |
|---|---|
| ការគ្រប់គ្រងបុគ្គលិកអប់រំកុមារតូច | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការគ្រប់គ្រងសិស្ស | - គ្រប់គ្រងទិន្នន័យកុមារអាយុ០៣ឆ្នាំដល់ក្រោម០៦ឆ្នាំ<br>- រៀបចំផែនទីសិក្សាសម្រាប់ការអប់រំកុមារតូច<br>- រៀបចំសិស្សទៅតាមនិយាម និងតាមកម្រិតអាយុ<br>- ពិនិត្យសុខភាព និងអនាម័យស្របតាមស្តង់ដាអប្បបរមាផ្នែកសុខភាពសិក្សា<br>- តាមដាន និងទំនាក់ទំនងជាមួយឪពុកម្តាយ អ្នកអាណាព្យាបាលកុមារ<br>- តាមដានលទ្ធផលការអភិវឌ្ឍកុមារតូច |
| ការរៀបចំផែនការអប់រំ កុមារតូច | - ដាក់បញ្ចូលផែនការអប់រំកុមារតូចទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក<br>- រៀបចំផែនការផ្តែកលើលទ្ធផលស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច |
| ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំកុមារតូច | - លើកគម្រោងផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងរយៈពេលវែង<br>- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំ<br>- គ្រប់គ្រងកិច្ចបញ្ជិកាគណនេយ្យ<br>- រៀបចំបញ្ជីសារពើភណ្ឌប្រចាំឆ្នាំរបស់សាលារៀន<br>- រៀបចំបញ្ជីសារពើភណ្ឌគោលសម្រាប់រយៈពេល៥ឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក<br>- រៀបចំបញ្ជីតាមដានសម្ភារ បរិក្ខារក្នុងអង្គភាពឱ្យបានចំនួន២ដងក្នុងមួយឆ្នាំ<br>- រៀបចំតារាងតាមដានការកើនឡើង ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ<br>- រៀបចំកិច្ចបញ្ជិកាសម្ភារតាមនីតិវិធីឃ្លាំង<br>- លើកគម្រោងតម្រូវការសម្ភារប្រចាំឆ្នាំ |
| ការគ្រប់គ្រងទំនិញ សំណង់ អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំកុមារតូច | - ធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ<br>- ធ្វើផែនការកែតម្រូវប្រចាំឆ្នាំ<br>- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងបញ្ជូនមកតាមមុខសញ្ញាពាក់ព័ន្ធ |

| មុខងារ | សកម្មភាព |
|---|---|
| ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើកបន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន កម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ | - អនុលោមសេចក្តីណែនាំលេខ១៩ អយក.សសន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងអប់រំ យុវជន និងកីឡា |
| **ការគ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច** | |
| ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ | - ស្រង់ទិន្នន័យកុមារពីអាយុ០៣ឆ្នាំដល់ក្រោម០៦ឆ្នាំ(រកកុមារដែលបានចូលរៀន និងកុមារដែលមិនបានចូលរៀននៅតាមភូមិ)<br>- សាងសង់អគារ ជួសជុលអគារតាមស្តង់ដា<br>- រៀបចំផែនការអភិវឌ្ឍសាលារៀនប្រចាំឆ្នាំ<br>- រៀបចំ និងគាំទ្រដំណើរការគណៈកម្មការទ្រទ្រង់សាលា និងក្រុមផ្សេងៗប្រចាំសាលា<br>- រៀបចំទីធ្លា និងល្បែងក្រៅថ្នាក់តាមស្តង់ដា<br>- រៀបចំប្រជុំថ្ងៃព្រហស្បតិ៍ឱ្យបានទៀងទាត់តាមការកំណត់<br>- ផលិតសម្ភារឧបទេសតាមកម្មវិធីប្រចាំខែ<br>- ទំនាក់ទំនង និងជំរុញឪពុកម្តាយកុមារដែលមានកូនដល់អាយុចូលរៀន ដើម្បីឱ្យបញ្ជូនកូនមកសាលារៀន និងរៀនឱ្យបានទៀងទាត់ និងឧបត្ថម្ភគាំទ្រសាលាតាមលទ្ធភាព<br>- ការចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀន<br>- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងស្ថានភាពហិរញ្ញវត្ថុ តាមការកំណត់ |
| កម្មវិធីមត្តេយ្យសិក្សាឯកជន | - ធ្វើផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំសម្រាប់ មត្តេយ្យសិក្សា<br>- គ្រប់គ្រងទិន្នន័យសិស្សមត្តេយ្យសិក្សាប្រចាំឆ្នាំ<br>- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្របដោយមិនមានការរើសអើង<br>- ជ្រើសរើសសិស្សឱ្យចូលរៀនតាមលក្ខណៈវិនិច្ឆ័យនិងគោលការណ៍របស់សាលារៀន<br>- ធានាដំណើរការបង្រៀននិងរៀនឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាព<br>- គោរព និងអនុវត្តសាពចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- ធានាសណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តចំពោះសិស្ស<br>- ចុះពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តរបស់សាលារៀន<br>- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជូនក្រសួងអប់រំ យុវជន និងកីឡា |

| មុខងារ | សកម្មភាព |
|---|---|
| **កម្មវិធីនានាដែលត្រូវបំពេញបន្ថែមឱ្យសេវាអប់រំកុមារតូច** | |
| កម្មវិធីអប់រំបញ្ចូលគ្នា និងកម្មវិធីពហុភាសា | - ស្រង់ទិន្នន័យកុមារពិការស្រាលៗ និងកុមារជនជាតិដើមភាគតិច<br>- កំណត់ជ្រើសរើសកុមារ និងជ្រើសរើសសាលា/ថ្នាក់ដើម្បីអនុវត្ត<br>- ផលិតសម្ភារឧបទេសតម្រូវទៅតាមកុមារពិការ កុមារជនជាតិដើមភាគតិច<br>- ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់គ្រូបង្រៀន<br>- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍន៍ភាពតាមការកំណត់ |
| កម្មវិធីអាហារូបត្ថម្ភ | - ទំនាក់ទំនងជាមួយអង្គការដៃគូអភិវឌ្ឍពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដើម្បីកៀរគរធនធាន<br>- កំណត់ចំនួនកុមារដែលត្រូវទទួលអាហារូបត្ថម្ភ<br>- ជំរុញសហគមន៍ និងឪពុកម្ដាយកុមារឱ្យចូលរួមដាំដំណាំ ចិញ្ចឹមសត្វ ចូលរួមជាថវិកា សម្ភារនិងចំណាយពេលជួយចម្អិនអាហារ<br>- ទំនាក់ទំនងជាមួយមន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាព ដើម្បីស្វែងយល់ពីក្បួនធ្វើអាហារូបត្ថម្ភ |
| កម្មវិធីជួយកុមារក្រីក្រតាមសាលា | - ចងក្រងទិន្នន័យកុមារក្រីក្រតាមសាលា<br>- កំណត់ជ្រើសរើសកុមារក្រីក្រតាមសាលា<br>- ទំនាក់ទំនងអ្នកពាក់ព័ន្ធ ដើម្បីប្រមូលធនធាន(អង្គការដៃគូ សប្បុរសជន សហគមន៍ ព្រះសង្ឃ ស្ថាប័ននានា)<br>- កំណត់ពេលវេលាត្រូវផ្ដល់ធនធានឱ្យកុមារក្រីក្រ (អាច១ឆ្នាំផ្ដល់ឱ្យ១ដង ឬ១ឆ្នាំផ្ដល់ឱ្យ២ដង តាមលទ្ធភាពដែលមាន)<br>- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលការជួយកុមារក្រីក្រ |
| កម្មវិធីអប់រំមាតាបិតា ផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងកម្មវិធីមត្តេយ្យសិក្សាសហគមន៍ | - កំណត់និងជ្រើសរើសសាលាដែលត្រូវអនុវត្ត<br>- រៀបចំចងក្រងក្រុមមាតាបិតានៅតាមសាលា/ថ្នាក់គោលដៅ<br>- រៀបចំការប្រជុំតាមការណែនាំ(១ខែប្រជុំម្ដង)<br>- ចុះពិនិត្យតាមដានការអនុវត្តរបស់មាតាបិតាបង្គោល ប្រធានក្រុមម្ដាយ និងមាតាបិតាកុមារ<br>- រៀបចំរបាយការណ៍ ស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីមាតាបិតាផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សា សហគមន៍(ការប្រែប្រួល) ផ្ដល់ឱ្យអ្នកពាក់ព័ន្ធ។ |

**ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ១៩១...អនក្រ.បក ចុះថ្ងៃទី...១៤...ខែ កញ្ញា....ឆ្នាំ២០១៦**
**ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច**
**ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក**

| មុខងារ | សកម្មភាព |
|---|---|
| ការគ្រប់គ្រងបុគ្គលិកអប់រំបឋមសិក្សា | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សាជាប់កិច្ចសន្យា | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការគ្រប់គ្រងសិស្សបឋមសិក្សា | - យុទ្ធនាការប្រមូលសិស្សចូលរៀន<br>- រៀបចំស្រង់ស្ថិតិ<br>- ផែនទីខ្នងផ្ទះ ( រៀបចំ និងធ្វើបច្ចុប្បន្នភាព )<br>- រៀបចំសិស្ស និងគ្រូតាមថ្នាក់តាមនិយាម<br>- តាមដានវត្តមានសិស្ស |
| ការរៀបចំផែនការសម្រាប់ការអប់រំបឋមសិក្សា | - រៀបចំផែនការអភិវឌ្ឍសាលារៀន<br>- បែងចែកតួនាទី ភារកិច្ចរបស់មន្ត្រីអប់រំ<br>- បញ្ចូលផែនការអភិវឌ្ឍសាលារៀនទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក<br>- បែងចែកកម្មវិធីសិក្សាតាមកម្រិតថ្នាក់<br>- លើកគម្រោងថវិកាទៅតាមតម្រូវការផែនការអភិវឌ្ឍ |
| ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំបឋមសិក្សា | - រៀបចំតារាងតម្លាភាព<br>- រៀបចំបញ្ជីតាមដានថវិកា<br>- បែងចែកថវិកាតាមខ្ទង់គណនី<br>- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ<br>- រៀបចំបញ្ជី និងជម្រះបញ្ជីសារពើភណ្ឌតាមឆ្នាំ<br>- បិទស្លាកលើសម្ភារតាមប្រភពថវិកា<br>- រៀបចំបញ្ជីទទួល និងបែងចែកសម្ភារ |
| ការផ្តត់ផ្គង់សៀវភៅសិក្សាគោល | - លើកតម្រូវការសៀវភៅសិក្សាតាមឆ្នាំសិក្សា<br>- ស្នើសុំថវិកាសម្រាប់ទិញសៀវភៅសិក្សា<br>- បែងចែកដល់សិស្ស គ្រូតាមតម្រូវការ<br>- រៀបចំស្ថិតិគ្រប់គ្រង ថែរក្សាសៀវភៅសិក្សា<br>- ធ្វើរបាយការណ៍បូកសរុបពាក់ព័ន្ធនឹងសៀវភៅសិក្សា |
| ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាង | - រៀបចំបញ្ជីសម្រង់ឈ្មោះសាលារៀនបឋមសិក្សា |

| មុខងារ | សកម្មភាព |
|---|---|
| សង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំបឋមសិក្សា | - រៀបចំបញ្ជីតម្រូវការសាងសង់ និងជួសជុល<br>- រៀបចំផែនការថវិកាសម្រាប់ការសាងសង់ និងជួសជុល<br>- រៀបចំប្លង់សាងសង់ ប្លង់ជួសជុលលម្អិតបច្ចេកទេស បញ្ជីប៉ាន់តម្លៃប្រតិទិនការងារសាងសង់ និងជួសជុល<br>- រៀបចំប្លង់ទីតាំង (ប្លង់សាងសង់តាមស្តង់ដារបស់ក្រសួងអប់រំ យុវជន និងកីឡា)<br>- រៀបចំផែនការសម្រាប់តាមដាន និងត្រួតពិនិត្យការសាងសង់ និងការជួសជុល<br>- រៀបចំផែនការលទ្ធកម្ម<br>- ធ្វើផែនការកែតម្រូវ<br>- រៀបចំរបាយការណ៍ ប្រចាំត្រីមាស ឆមាស និងឆ្នាំដើម្បីផ្ញើទៅអង្គភាពដែលពាក់ព័ន្ធ |
| ការគ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន | - ជ្រើសរើសគណៈកម្មការទ្រទ្រង់សាលារៀន<br>- សម្របសម្រួលការប្រជុំ (៣ដងក្នុង១ឆ្នាំ)<br>- ចូលរួមកសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន<br>- ប្រមូល និងជំរុញកុមារឱ្យចូលរៀន<br>- តាមដានការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ<br>- កៀរគរថវិកាដើម្បីអភិវឌ្ឍសាលារៀន<br>- ចូលរួមកសាង ថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន<br>- ចូលរួមទប់ស្កាត់រាល់បាតុភាពមិនប្រក្រតីទាំងក្នុង និងក្រៅសាលា<br>- វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍសាលារៀន |
| គណៈកម្មាការអភិវឌ្ឍន៍កម្រងសាលារៀន | - បង្កើត លុបកម្រងសាលារៀន<br>- សម្របសម្រួលយន្តការកម្រងសាលារៀន<br>- សម្របសម្រួលការប្រជុំបច្ចេកទេសក្នុងកម្រងសាលារៀន<br>- សម្របសម្រួលការចែករំលែកធនធាន សម្ភាររវាងកម្រងមួយទៅកម្រងមួយ និងរវាងសាលាមួយទៅសាលាមួយទៀត<br>- ពិនិត្យតាមដានការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មការ និងក្រុមប្រឹក្សាកម្រងសាលារៀន<br>- តាមដានលទ្ធផលសិក្សាក្នុងកម្រង<br>- ការប្រឡងប្រណាំង រវាងកម្រងនិងក[illegible] និង[illegible] និង[illegible]លា |
| ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្តោះ អាសន្ន និង | អនុលោមសេចក្តីណែនាំលេខ១០ អយ[illegible]២[illegible] ខែមករា ឆ្នាំ២០១៤ |

| **មុខងារ** | **សកម្មភាព** |
|---|---|
| ការដេកហូតអាជ្ញាប័ណ្ណសាលាបឋមសិក្សាឯកជនកម្មវិធីសិក្សាជាតិ | |
| **ការគ្រប់គ្រងកម្មវិធីការងារគាំទ្រ ការអប់រំបឋមសិក្សា៖** | |
| កម្មវិធីពហុភាសា | - រៀបចំថ្នាក់រៀនដែលស្ថិតនៅតំបន់ជនជាតិដើមភាគតិច<br>- ប្រមូលសិស្សជនជាតិដើមភាគតិចដែលមានតម្រូវការ<br>- រៀបចំផែនការដើម្បីបណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រង និងគ្រូសម្រាប់ការបង្រៀនពហុភាសា<br>- ជំរុញការអនុវត្តកម្មវិធីសិក្សាថ្នាក់ពហុភាសា<br>- រៀបចំរបាយការណ៍បូកសរុបការអនុវត្តដំណើរការបង្រៀនពហុភាសា |
| កម្មវិធីពន្លឿនការសិក្សា | - ប្រមូល និងគ្រប់គ្រងស្ថិតិសិស្ស ឬកុមារលើសអាយុ<br>- រៀបចំថ្នាក់ និងគ្រូសម្រាប់ការបង្រៀនកម្មវិធីពន្លឿនការសិក្សា<br>- ជំរុញការអនុវត្ត និងធ្វើរបាយការណ៍លទ្ធផល |
| កម្មវិធីស្បៀងអាហារតាមសាលារៀន | - រៀបចំកន្លែងចម្អិនអាហារ( ផ្ទះបាយតាមសាលារៀន ) និងចុងភៅដោយកៀរគរធនធានពីសហគមន៍<br>- រៀបចំតារាងបញ្ជីឈ្មោះសិស្សតាមវេន ដែលត្រូវទទួលអាហារ<br>- ធ្វើសំណើសុំស្បៀងដើម្បីប្រើប្រាស់ទៅតាមត្រីមាស ដែលផ្អែកលើចំនួនសិស្សដែលបានប៉ាន់ស្មាន<br>- រៀបចំទុកដាក់ស្បៀងអាហារឱ្យបានត្រឹមត្រូវតាមបច្ចេកទេស<br>- បែងចែកស្បៀង និងចម្អិនអាហារឱ្យសិស្សហូប<br>- កៀរគរធនធានពីសហគមន៍ដើម្បីឧបត្ថម្ភចុងភៅ<br>- រៀបចំរបាយការណ៍ |
| កម្មវិធីអប់រំពិសេស | - កំណត់អត្តសញ្ញាណសិស្សពិការ<br>- សម្របសម្រួល និងផ្តល់នូវការគាំទ្រដល់សិស្សពិការ<br>- រៀបចំសិស្សពិការឱ្យចូលរៀនជាមួយសិស្សធម្មតា<br>- អភិវឌ្ឍសមត្ថភាពគ្រូលើការអប់រំបរិយាប័ន្ន |
| កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ | - បង្កើតគណៈកម្មការ<br>- ជ្រើសរើសសិស្សអាហារូបករណ៍( ផ្អែកតាមការណែនាំរបស់ក្រសួង )<br>- រៀបចំផែនការថវិកា និងសំណើសុំអាហារូបករណ៍<br>- បែងចែកថវិកាដល់សិស្សអាហារូបករណ៍ដែលបានជ្រើសរើស<br>- តាមដានការសិក្សារបស់សិស្សដែលទទួលបានអាហារូបករណ៍<br>- រៀបចំរបាយការណ៍បូកសរុប។ |
| កម្មវិធីអប់រំសុខភាព និងអនាម័យ | - សាលារៀនសុវត្ថិភាព បំប៉នក្រុមបំប៉ន និងពិនិត្យតាមដានលទ្ធផល |

| មុខងារ | សកម្មភាព |
| --- | --- |
| | ក្រុង ស្រុក គ្រូបង្រៀន សហគមន៍ និងអ្នកពាក់ព័ន្ធអំពីការបង្ការគ្រោះថ្នាក់ផ្សេងៗ គ្រោះថ្នាក់ដោយធម្មជាតិ និងដោយសារគ្រាប់សំណល់ពីសង្គ្រាម ធ្វើរបងព័ទ្ធជុំវិញស្រះទឹក អណ្តូងទឹកនៅក្នុងសាលារៀន<br>- បង្កើតគណៈកម្មការសុខភាពសិក្សាតាមសាលារៀន<br>- ត្រួតពិនិត្យមើលសុខភាពរបស់កុមារមុនចាប់ផ្តើមចូលរៀន (ពិនិត្យសុខភាព និងកាយសម្បទាកុមារថ្នាក់ទី១ នៅពេលចាប់ផ្តើមឆ្នាំសិក្សាដំបូង។ ផ្តល់វ៉ាក់សាំងថ្នាំបង្ការ ផ្តល់វីតាមីន ផ្តល់ថ្នាំទម្លាក់ព្រូនពីរដង ក្នុងមួយឆ្នាំដល់បុគ្គលិកអប់រំ និងអ្នកសិក្សា)។<br>- ការពិនិត្យចំណីអាហារនៅក្នុងសាលារៀន ការបំពាក់សម្ភារបរិក្ខារផ្នែកអនាម័យតាមសាលារៀន (ផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ ផ្តល់ប្រអប់សង្គ្រោះបឋម និងសម្ភារៈបម្រុង គ្រប់គ្រងកាកសំណល់រឹង រាវ និងរៀបចំ និងរក្សាទុកព័ត៌មានសុខភាពរបស់សិស្សនៅគ្រប់កម្រិតសិក្សា)<br>- ការអប់រំសុខភាព(ផ្តល់ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមបញ្ចូលទាំងការអប់រំ បង្ការជំងឺអេដស៍ គ្រឿងញៀន ការអប់រំសុខភាព អនាម័យ សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ វិធីសង្គ្រោះបឋម គ្រឿងស្រវឹង បារី សុខភាពភ្នែក សុខភាពមាត់ធ្មេញ ព្រមទាំងការអប់រំបង្ការជំងឺមិនឆ្លង និងជំងឺឆ្លងនានា)<br>- ការអប់រំអំពីសង្គម និងបរិស្ថាន(បំប៉នគ្រូបង្រៀន សិស្ស និងអ្នកពាក់ព័ន្ធអំពីវិធានការបង្ការទប់ស្កាត់ គ្រោះមហន្តរាយ គ្រោះថ្នាក់ផ្សេងៗ បម្រែបម្រួលអាកាសធាតុ ការដាំដើមឈើឡើងវិញ និងការថែរក្សាបរិស្ថាន ។ |
| ការងារក្រុមប្រឹក្សាកុមារ | - រៀបចំយន្តការ ការគ្រប់គ្រង និងការជ្រើសរើសក្រុមប្រឹក្សាកុមារ<br>- គាំទ្រដល់ដំណើរការរបស់ក្រុមប្រឹក្សាកុមារ<br>- លើកទឹកចិត្តដល់ក្រុមប្រឹក្សាកុមារផ្តោតលើចលនាបីល្អ |
| ការអប់រំកាយ និងកីឡា | - ជំរុញ និងតាមដានសកម្មភាពកាយសិក្សានៅតាមសាលាបឋមសិក្សាសាធារណៈ និងឯកជន<br>- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមសាលាបឋមសិក្សាសាធារណៈ និងឯកជន |

**ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦**
**ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច**
**ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក**

| មុខងារ | សកម្មភាព |
|---|---|
| ការគ្រប់គ្រងបុគ្គលិកអប់រំក្រៅប្រព័ន្ធ | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម | - ផ្សព្វផ្សាយកម្មវិធីអប់រំក្រៅប្រព័ន្ធដល់អ្នកពាក់ព័ន្ធ<br>- ពិនិត្យ ស្រង់ស្ថិតិ និងប្រមូលក្រុមមុខសញ្ញា<br>- រៀបចំឯកសារ និងសម្ភារសម្រាប់ដំណើរការរៀន<br>- ពិនិត្យតាមដានការរៀនរបស់សិស្ស<br>- រៀបចំការប្រឡង និងបញ្ជូនសិស្ស<br>- ចេញប័ណ្ណអក្ខរកម្ម វិញ្ញាបនបត្របញ្ជាក់ការសិក្សាតាមកម្មវិធី |
| ការរៀបចំផែនការសកម្មភាព សម្រាប់ការអប់រំក្រៅប្រព័ន្ធ | - រៀបចំផែនទីសិក្សាពាក់ព័ន្ធកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>- រៀបចំផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាតាមឆ្នាំ<br>- សិក្សាតម្រូវការឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្រុមមុខសញ្ញា<br>- ចូលរួមវគ្គបំប៉នទាក់ទងនឹងការរៀបចំផែនការសកម្មភាព<br>- រៀបចំផែនការការងារលម្អិតតាមខែ<br>- រៀបចំផែនការការងារប្រចាំឆ្នាំ |
| ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់ការអប់រំក្រៅប្រព័ន្ធ | - បង្កើតគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ<br>- រៀបចំផែនការចំណាយប្រចាំឆ្នាំ ប្រចាំខែ<br>- រៀបចំការបែងចែកថវិកាទៅកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>- រាល់ការចំណាយត្រូវមានការឯកភាពតាមគណៈកម្មការនីមួយៗ និងតម្លាភាព<br>- រៀបចំកិច្ចបញ្ជិកាគណនេយ្យ<br>- រៀបចំបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំរបស់សាលា<br>- រៀបចំបញ្ជីសារពើភ័ណ្ឌគោលរបស់ក្រុង ស្រុក<br>- តាមដានការកើនឡើង ការថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ<br>- ធ្វើការពិនិត្យតាមដានសម្ភារបរិក្ខាររបស់សាលា<br>- រៀបចំកិច្ចបញ្ជិកាសម្ភារ<br>- លើកគម្រោងតម្រូវការសម្ភារប្រចាំឆ្នាំ<br>- រៀបចំសៀវភៅបញ្ជីតាមដានការប្រើប្រាស់សម្ភារ |

| មុខងារ | សកម្មភាព |
|---|---|
| ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្តោះអាសន្ន និងការដកហូតអាជ្ញាប័ណ្ណមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមុខរបរ និងភាសាបរទេសរយៈពេលតិចជាង ០១(មួយ)ឆ្នាំ | - អនុលោមសេចក្តីណែនាំលេខ១៩ អយក.សសន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ |
| ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំក្រៅប្រព័ន្ធ | - រៀបចំបញ្ជីសម្រង់ឈ្មោះមជ្ឈមណ្ឌលសិក្សាសហគមន៍<br>- រៀបចំបញ្ជីតម្រូវការសាងសង់ និងជួសជុល<br>- រៀបចំផែនការថវិកាសម្រាប់ការសាងសង់ ការជួសជុល<br>- រៀបចំប្លង់សាងសង់ ប្លង់ជួសជុលលម្អិតបច្ចេកទេស បញ្ជីប៉ាន់តម្លៃប្រតិទិនការងារសាងសង់ និងជួសជុល<br>- រៀបចំប្លង់ទីតាំង ( ប្លង់សាងសង់កំណត់តាមស្តង់ដារបស់ក្រសួងអប់រំ យុវជន និងកីឡា )<br>- រៀបចំផែនការសម្រាប់តាមដាន និងត្រួតពិនិត្យការសាងសង់ និងជួសជុល<br>- រៀបចំផែនការលទ្ធកម្ម<br>- ធ្វើផែនការកែតម្រូវ<br>- របាយការណ៍ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ដើម្បីផ្ញើទៅអង្គភាពពាក់ព័ន្ធ |
| ការគ្រប់គ្រងដំណើរកម្មវិធី និងសេវាពាក់ព័ន្ធ | |
| កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ | - បើកថ្នាក់អក្ខរកម្មតាមភូមិឬមជ្ឈមណ្ឌលសិក្សាសហគមន៍ តាមរោងចក្រសហគ្រាស<br>- ផ្គត់ផ្គង់សម្ភារៈទ្រទ្រង់ដំណើរការថ្នាក់<br>- ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា<br>- ផ្តល់អាហារូបករណ៍ដល់សិស្សអក្ខរកម្ម<br>- ផ្តល់ការអប់រំអក្ខរកម្មពីរភាសាសម្រាប់ជនជាតិដើមភាគតិច<br>- ផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សអក្ខរកម្មដែលសិក្សាបានល្អ<br>- ពិនិត្យតាមដាន និងកែលម្អឱ្យបានជាប្រចាំ<br>- ប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ៨កញ្ញា |
| កម្មវិធីក្រោយអក្ខរកម្ម | - ផ្តល់ថវិកាដំណើរការបណ្ណាល័យ និងមណ្ឌលអាន<br>- សាកល្បងតេស្តថ្នាក់ក្រោយអក្ខរកម្មសម្រាប់អ្នក[illegible]បញ្ចប់ការសិក្សា<br>- ពិនិត្យតាមដានដំណើរការបណ្ណាល័យ និងមណ្ឌលអាន |

| មុខងារ | សកម្មភាព |
|---|---|
| កម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា | - ផ្សព្វផ្សាយកម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា<br>- ផ្តល់សម្ភារៈដំណើរការ<br>- ចូលរួមវគ្គបំប៉នគ្រូបង្រៀនជាប់កិច្ចសន្យា<br>- ពិនិត្យតាមដានលើការអនុវត្តកម្មវិធី<br>- រៀបចំការប្រឡង និងបញ្ជីឈ្មោះសិស្ស<br>- ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា |
| កម្មវិធីបង្កើនប្រាក់ចំណូល | - ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃមជ្ឈមណ្ឌលសិក្សាសហគមន៍ និងកម្មវិធីបំណិនជីវិត<br>- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលសហគមន៍តាមតម្រូវការជាក់ស្តែង<br>- ប្រជុំប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងរៀបចំរបាយការណ៍<br>- កំណត់អាទិភាពបណ្តុះបណ្តាលជំនាញមុខរបរឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ<br>- ផ្តល់ទុន ឬប្រាក់កម្ចី ឬសម្ភារៈដល់អ្នករៀននៅពេលបញ្ចប់ការសិក្សា<br>- ពិនិត្យតាមដានកែលម្អជាប្រចាំពីអ្នកពាក់ព័ន្ធនានា<br>- បើកថ្នាក់បង្រៀនថ្នាក់ជំនាញមុខរបរនៅតាមមជ្ឈមណ្ឌល សហគមន៍<br>- ជំរុញការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍<br>- ប្រើប្រាស់ស្តង់ដាវាយតម្លៃគ្រប់សកម្មភាព ស្ថានភាពមជ្ឈមណ្ឌលសិក្សាសហគមន៍<br>- ចូលរួមទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍<br>- សហការជាមួយសហគមន៍ពិនិត្យទីតាំងសមស្របសម្រាប់កសាងមជ្ឈមណ្ឌលសិក្សាសហគមន៍ |
| កម្មវិធីចូលរៀនឡើងវិញ | - ផ្តល់ការគាំទ្រគណៈកម្មការប្រមូលសិស្ស<br>- ផ្តល់សម្ភារៈសម្រាប់ដំណើរការថ្នាក់<br>- ចូលរួមវគ្គបំប៉ន |